ឆ្នាំទី ៣ លេខ ៨១-៨២ ថ្ងៃ ទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៣ រាជកិច្ច ទំព័រ ៣៣៣៦

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ០០៤ ស ជ

ភ្នំពេញ,ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០០៣

# សារាចរ

## ណែនាំអំពីការផ្ដល់ " ប័ណ្ណឆ្លងដែន " ជូនប្រជាពលរដ្ឋខ្មែរ និងការគ្រប់គ្រងការឆ្លងកាត់ព្រំដែន

ដើម្បីអោយប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅក្នុងខេត្តជាប់ព្រំដែនជាមួយនឹងព្រះរាជាណាចក្រថៃ មានលិខិតស្នាមសំរាប់ប្រើប្រាស់ជាផ្លូវការ ក្នុងការធ្វើដំណើរឆ្លងកាត់ច្រកទ្វារព្រំដែនកម្ពុជា-ថៃ ក៏ដូចជាដើម្បីបង្កលក្ខណៈងាយស្រួលដល់អាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងការចេញ-ចូលឆ្លងកាត់ព្រំដែន រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ បានព្រមព្រៀងគ្នាអោយបង្កើត **ប័ណ្ណឆ្លងដែន** សំរាប់ជូនប្រជាពលរដ្ឋប្រើប្រាស់ជាផ្លូវការចាប់ពីពេលនេះតទៅ ។

ក្រសួងមហាផ្ទៃសូមធ្វើការណែនាំដល់សមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ត្រូវយកចិត្តទុកដាក់ស្វែងយល់ និងអនុវត្តការងាររបស់ខ្លួនអោយមានប្រសិទ្ធភាព និងលទ្ធផលល្អប្រសើរដូចខាងក្រោម ៖

**I-<u>អំពីប័ណ្ណឆ្លងដែន</u> :**

១-**ប័ណ្ណឆ្លងដែន** គឺជាឯកសារសំរាប់ធ្វើដំណើរមានកំណត់ពេល និងទីកន្លែងច្បាស់លាស់ ស្របតាមខ្លឹមសារអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៣ ស្ដីពីការប្រើប្រាស់ប័ណ្ណឆ្លងដែននៅតាមច្រកទ្វារព្រំដែនកម្ពុជា-ថៃ របស់រាជរដ្ឋាភិបាលកម្ពុជា ។

ក្នុងជំហានដំបូងនេះ ប្រជាពលរដ្ឋខ្មែរអាចប្រើប្រាស់ប័ណ្ណឆ្លងដែន ក្នុងការធ្វើដំណើរពីខេត្តបន្ទាយមានជ័យនៃព្រះរាជាណាចក្រកម្ពុជាឆ្លងចូលទៅខេត្តប្រាជីនបុរី ដោយឆ្លងកាត់ខេត្តស្រះកែវនៃព្រះរាជាណាចក្រថៃ ។ ការឆ្លងកាត់នេះត្រូវមានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ក្នុងគោលបំណងទៅសាកសួរសុខទុក្ខញាតិសន្ដាន ពិនិត្យព្យាបាលជម្ងឺ ទេសចរណ៍ បំពេញភារកិច្ចផ្លូវការ ជំនួញ កីឡា ចូលរួមសិក្ខាសាលា កិច្ចប្រជុំ និងបំណងផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃបានព្រមព្រៀងគ្នា ។

២-អភិបាលខេត្តបន្ទាយមានជ័យ នៃព្រះរាជាណាចក្រកម្ពុជា លោកនាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ឬលោកនាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោក ប្រចាំការនៅច្រកទ្វារព្រំដែនរបស់ខេត្តបន្ទាយមានជ័យ ជាមន្ត្រីមានសមត្ថកិច្ចក្នុងការផ្តល់ប័ណ្ណឆ្លងដែន ។

៣-ប័ណ្ណឆ្លងដែនមាន ០២ប្រភេទ គឺប័ណ្ណឆ្លងដែនពណ៌ខៀវ និងប័ណ្ណឆ្លងដែនពណ៌លឿង:

-អភិបាលខេត្តបន្ទាយមានជ័យមានសិទ្ធិចេញប័ណ្ណឆ្លងដែនពណ៌ខៀវ ជូនប្រជាពលរដ្ឋដែលរស់នៅក្នុងខេត្តបន្ទាយមានជ័យ ។

-លោកនាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ឬលោកនាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោក ប្រចាំនៅច្រកទ្វារព្រំដែនរបស់ខេត្តបន្ទាយមានជ័យ មានសិទ្ធិចេញប័ណ្ណពណ៌លឿងជូនប្រជាពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តបន្ទាយមានជ័យ ។

៤-ក្រសួងមហាផ្ទៃជាអ្នកផ្គត់ផ្គង់ និងផ្តល់ប័ណ្ណឆ្លងដែនទាំង ០២ប្រភេទនេះ ជូនទៅខេត្តបន្ទាយមានជ័យ និងមានវិធានការបង្ការការផលិត និងប្រើប្រាស់ប័ណ្ណឆ្លងដែនក្លែងក្លាយ ។ល។

ប័ណ្ណឆ្លងដែនទីមួយៗ មានលក្ខណៈសំគាល់ដូចខាងក្រោម ÷

ក-នៅក្របខាងក្រៅមាន :

-រូបព្រះរាជសង្ហារពណ៌មាស និងរូបសញ្ញាក្រសួងមហាផ្ទៃពណ៌លឿង

-ក្រោមព្រះរាជសង្ហារមានសរសេរអក្សរខ្មែរថា "ព្រះរាជាណាចក្រកម្ពុជា "

-ក្រោមអក្សរខ្មែរមានអក្សរអង់គ្លេសថា " KINGDOM OF CAMBODIA "

-ក្រោមអក្សរអង់គ្លេសនៅចំកណ្តាលរូបសញ្ញាក្រសួងមហាផ្ទៃ មានសរសេរអក្សរខ្មែរថា " ប័ណ្ណឆ្លងដែន "

-ក្រោមអក្សរខ្មែរមានអក្សរអង់គ្លេសថា " **Border Pass** "

-ក្រោមអក្សរអង់គ្លេសមានសរសេរថា លេខ:...............

ខ-នៅខាងក្នុងប័ណ្ណឆ្លងដែនមានកំណត់អំពីលក្ខណៈសំគាល់របស់អ្នកកាន់ប័ណ្ណឆ្លងដែនម្នាក់ៗដូចតទៅ:

-នាមត្រកូល:...............................

-នាមខ្លួន:...............................

-ថ្ងៃខែឆ្នាំកំណើត:............................ ភេទ:...........

-ទីកន្លែងកំណើត:...........................

-មុខរបរ:...................................

-អត្តសញ្ញាណប័ណ្ណលេខ:...................

-មានស្នាមពិសេស: ........................

-អាស័យដ្ឋាន:...............................

-កន្លែងបិទរូបថត:

-ហត្ថលេខា ឬស្នាមផ្តិតមេដៃស្តាំ:......................

-ធ្វើនៅ............... ផ្តល់នៅថ្ងៃទី ..................

-ផុតកំណត់ថ្ងៃទី.......................................

-ហត្ថលេខា និងត្រាមន្ត្រីអន្តោប្រវេសន៍:..............

ចំពោះប័ណ្ណឆ្លងដែនដែលបញ្ចូលឈ្មោះកូនស្របច្បាប់របស់អ្នកកាន់ប័ណ្ណឆ្លងដែន (អាយុក្រោម ១២ឆ្នាំ) ត្រូវមានកំណត់លក្ខណៈសំគាល់របស់កូនស្របច្បាប់ទាំងនោះដូចតទៅ :

-នាមត្រកូល និងនាមខ្លួន:................

-ភេទ:............

-ថ្ងៃ ខែ ឆ្នាំកំណើត:......................

-ទីកន្លែងកំណើត:........................

-កន្លែងបិទរូបថត:

លក្ខណៈសំគាល់ផ្សេងៗដូចបានរៀបរាប់ខាងលើ ត្រូវសរសេរបំពេញក្នុងប័ណ្ណឆ្លងដែនជាអក្សរខ្មែរ និងអង់គ្លេស ។ អក្សរបំពេញលក្ខណៈសំគាល់ចុះក្នុងប័ណ្ណឆ្លងដែន ត្រូវសរសេរអោយបានច្បាស់ មិនត្រូវកោសលុប ឬសរសេរជ្រៀតថែមឡើយ ។

៥-ប័ណ្ណឆ្លងដែនមានសុពលភាពសំរាប់រយៈពេល ០២ឆ្នាំ គិតចាប់ពីថ្ងៃចេញប័ណ្ណ ។ ផុតកំណត់រយៈពេលប្រើប្រាស់ អ្នកកាន់ប័ណ្ណឆ្លងដែនត្រូវស្នើសុំប័ណ្ណថ្មី ។

## II-<u>អំពីនីតិវិធីនៃការផ្តល់ និងការប្រើប្រាស់ប័ណ្ណឆ្លងដែន</u> :

១-ជំហានដំបូងនេះ ប័ណ្ណឆ្លងដែនត្រូវបានផ្តល់ជូនចំពោះតែប្រជាពលរដ្ឋខ្មែរ ដែលមានអាយុចាប់ពី ១២ឆ្នាំឡើង ហើយជាអ្នកស្នាក់នៅអចិន្ត្រៃយ៍ក្នុងខេត្តបន្ទាយមានជ័យនៃព្រះរាជាណាចក្រកម្ពុជា ។

២-អ្នកស្នើសុំប័ណ្ណឆ្លងដែនជាពលរដ្ឋខ្មែរ ដែលត្រូវជាឪពុក ឬម្តាយ អាចសុំបំពេញបែបបទសំរាប់បញ្ចូលក្នុងប័ណ្ណឆ្លងដែនរបស់ខ្លួននូវកូនស្របច្បាប់ អាយុក្រោម ១២ឆ្នាំ ដែលត្រូវរួមដំណើរជាមួយ ។

៣-ប័ណ្ណឆ្លងដែននឹងមិនត្រូវផ្តល់ជូនចំពោះជនប្រព្រឹត្តបទល្មើសអំពីគ្រឿងញៀន វត្ថុបូរាណ ការជួញដូរមនុស្ស ជនវិកលចារិក ជនដែលកំពុងស្ថិតនៅក្នុងស្ថានភាពជាទណ្ឌិត និងពិរុទ្ធជន ។

៤-អ្នកស្នើសុំប័ណ្ណឆ្លងដែនអាចដាក់ពាក្យស្នើសុំនៅសាលាខេត្តបន្ទាយមានជ័យ ឬនៅប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ឬនៅប៉ុស្តិ៍នគរបាលការពារព្រំដែនគោកប្រចាំច្រកទ្វារព្រំដែន ដែលស្ថិតនៅក្នុងខេត្តបន្ទាយមានជ័យ តាមរយៈមេឃុំ លោកអភិបាលស្រុក នៃទីកន្លែងដែលសាមីខ្លួនស្នាក់នៅអចិន្ត្រៃយ៍ ដោយភ្ជាប់មកជាមួយនូវ : <

-ពាក្យស្នើសុំដែលមានការបញ្ជាក់ទទួលស្គាល់ពីមេឃុំ និងអភិបាលស្រុក ០១ច្បាប់ ដោយបិទតែមប្រ៍ ។

-ជីវប្រវត្តិសង្ខេប ចំនួន ០១ច្បាប់

-លិខិតបញ្ជាក់ទីលំនៅដែលចេញដោយមេឃុំ ឬច្បាប់ចំលងអត្តសញ្ញាណប័ណ្ណ ឬសេចក្តីចំលងសំបុត្រកំណើត ០១ច្បាប់ ។

-រូបថត ៤ × ៦ ចំនួន ០៣សន្លឹក (ថតចំពីមុខគ្មានពាក់មួក និងវ៉ែនតាពណ៌ខ្មៅ)

-លិខិតអនុញ្ញាតពីឪពុកម្តាយ ឬអាណាព្យាបាល ប្រសិនបើជាអនីតិជន ។

-អ្នកស្នើសុំប័ណ្ណឆ្លងដែនមានភារកិច្ចបង់ថ្លៃប័ណ្ណឆ្លងដែន និងថ្លៃលិខិតស្នាមផ្សេងៗ សំរាប់បំរើការផ្តល់ប័ណ្ណឆ្លងដែនជូនអាជ្ញាធរមានសមត្ថកិច្ច ដែលផ្តល់ប័ណ្ណឆ្លងដែនប្រភេទនីមួយៗ ស្មើនឹងទឹកប្រាក់ចំនួន ២០.០០០ រៀល (ម្ភៃពាន់រៀល) ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវចេញបង្កាន់ដៃទទួលប្រាក់ជូនប្រជាពលរដ្ឋដែលបានបង់ថ្លៃរួច ហើយត្រូវចុះបញ្ជីគ្រប់គ្រងដោយឡែក និងរក្សាទុកគល់បញ្ជីបង្កាន់ដៃទទួលប្រាក់អោយបានត្រឹមត្រូវ និងគង់វង្សល្អ ។

៦-អ្នកកាន់ប័ណ្ណឆ្លងដែនដែលចេញដោយអភិបាលខេត្តបន្ទាយមានជ័យ ឬដោយនាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ឬដោយនាយប៉ុស្តិ៍នគរបាលព្រំដែនគោក ប្រចាំច្រកទ្វារព្រំដែន អាចធ្វើដំណើរចូលទៅខេត្តប្រាជីនបុរីរបស់ព្រះរាជាណាចក្រថៃបាន ដោយឆ្លងកាត់តាមខេត្តស្រះកែវ ។

ក្នុងការធ្វើដំណើរចូល និងស្នាក់នៅក្នុងខេត្តស្រះកែវ ឬខេត្តប្រាជីនបុរីនៃព្រះរាជាណាចក្រថៃម្តងៗ អ្នកកាន់ប័ណ្ណអាចស្នាក់នៅបានរយៈពេល ០៧ថ្ងៃ ។ ចំពោះការស្នាក់នៅដែលមានរយៈពេលលើសពីនេះ តែមិនហួសពី ១៥ថ្ងៃ ត្រូវសុំការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនៃខេត្តដែលសាមីជនស្នាក់នៅ ។

៧-ចំពោះប្រជាពលរដ្ឋថៃអាចធ្វើដំណើរចេញពីខេត្តស្រះកែវ មកខេត្តសៀមរាបដោយឆ្លងកាត់ខេត្តបន្ទាយមានជ័យ ។ ក្នុងការធ្វើដំណើរចូល និងស្នាក់នៅក្នុងខេត្តបន្ទាយមានជ័យ ឬខេត្តសៀមរាបនៃព្រះរាជាណាចក្រកម្ពុជា អ្នកកាន់ប័ណ្ណអាចស្នាក់នៅបានរយៈពេល ០៧ថ្ងៃ ។ ចំពោះការស្នាក់នៅដែលមានរយៈពេលលើសពីនេះ តែមិនហួសពី ១៥ថ្ងៃ ត្រូវសុំការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនៃខេត្តដែលសាមីខ្លួនស្នាក់នៅ ។

៨-នៅពេលធ្វើដំណើរចេញ-ចូលខេត្តជាប់ព្រំដែន តាមច្រកដែលអនុញ្ញាតអោយចេញ-ចូល អ្នកកាន់ប័ណ្ណឆ្លងដែនត្រូវបង្ហាញប័ណ្ណរបស់ខ្លួនជូនមន្ត្រីអន្តោប្រវេសន៍ ដែលកំពុងបំពេញភារកិច្ចនៅច្រកដែលខ្លួនចេញចូល ដើម្បីចុះបញ្ជី និងបោះត្រាអនុញ្ញាត ។

៩-អ្នកកាន់ប័ណ្ណឆ្លងដែនត្រូវរក្សាប័ណ្ណរបស់ខ្លួនអោយបានគង់វង្សល្អ មិនត្រូវអោយអ្នកដទៃខ្ចីយកទៅប្រើ កោសលុបសរសេរថែម ឬធ្វើអោយខូចទ្រង់ទ្រាយដើមនៃប័ណ្ណឆ្លងដែនរបស់ខ្លួនឡើយ ។

នៅពេលមានការខូចខាត ឬបាត់បង់ប័ណ្ណឆ្លងដែនដោយប្រការណាមួយ អ្នកកាន់ប័ណ្ណឆ្លងដែនត្រូវរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ច ដែលចេញប័ណ្ណនោះ ។

ជនណាក្លែងបន្លំប័ណ្ណឆ្លងដែននឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

១០-នៅពេលឆ្លងចូលទៅខេត្តជាប់ព្រំដែនដែលបានអនុញ្ញាត អ្នកកាន់ប័ណ្ណឆ្លងដែនត្រូវគោរពច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅទីនោះ ។

អ្នកកាន់ប័ណ្ណឆ្លងដែនដែលធ្វើដំណើរហួសពីតំបន់ដែលបានកំណត់ នឹងត្រូវទទួលរងការផ្តន្ទាទោសតាមច្បាប់អន្តោប្រវេសន្ត និងបទប្បញ្ញត្តិជាធរមាននៅប្រទេសដែលខ្លួនឆ្លងចូលទៅនោះ ។

**III-អំពីការគ្រប់គ្រងការឆ្លងកាត់ព្រំដែន :**

១-ចាប់ពីពេលនេះទៅ អភិបាលខេត្ត ក្រុង លោកនាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិនានា ឬលោកនាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោកប្រចាំការនៅច្រកទ្វារព្រំដែនរបស់ខេត្ត ក្រុងនីមួយៗ ដែលនៅជាប់ព្រំប្រទល់ជាមួយព្រះរាជាណាចក្រថៃ ត្រូវផ្អែកតាមស្មារតីនៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការឆ្លងកាត់ព្រំដែនរវាងប្រទេសទាំង២ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ និងកិច្ចព្រមព្រៀងអង្គប្រជុំគណៈរដ្ឋមន្ត្រីចំរុះកម្ពុជា-ថៃ នាថ្ងៃទី៣១ ខែឧសភា និងថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៣ ដើម្បីពិនិត្យវាយតំលៃសភាពការណ៍សន្តិសុខជាក់ស្តែងនៅតំបន់ព្រំដែន រួចធ្វើសេចក្តីរាយការណ៍បញ្ជាក់អំពីស្ថានភាពជាក់ស្តែងនៃច្រកទ្វារព្រំដែននីមួយៗ តើច្រកទ្វារព្រំដែនណា ដែលអាចបើកដំណើរការបាន និងមិនទាន់អាចដំណើរការបាន ផ្ញើតាមឋានានុក្រមមកក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងសំរេចអនុញ្ញាតអោយដំណើរការ ។

២-ចំពោះច្រកទ្វារព្រំដែនដែលត្រូវអនុញ្ញាតអោយដំណើរការបាន ក្នុងពេលដំណើរការ អភិបាលខេត្ត ក្រុងពាក់ព័ន្ធ អគ្គស្នងការដ្ឋាននគរបាលជាតិ និងនាយកដ្ឋានជំនាញ ត្រូវណែនាំដល់គ្រប់ភ្នាក់ងារមានសមត្ថកិច្ចអោយគ្រប់គ្រងការចេញ-ចូលឆ្លងកាត់ព្រំដែនរបស់ប្រជាពលរដ្ឋខ្មែរ និងជនបរទេសអោយបានត្រឹមត្រូវ ខិតខំការពារសន្តិសុខ រក្សាសណ្តាប់ធ្នាប់សាធារណៈតាមច្រកទ្វារព្រំដែននីមួយៗ និងទប់ស្កាត់អោយបានដាច់ខាតការឆ្លងកាត់ព្រំដែនដោយខុសច្បាប់ ។

៣-អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវណែនាំដល់កងកំលាំងនគរបាលអន្តោប្រវេសន្ត និងកងកំលាំងនគរបាលការពារព្រំដែនគោក ដែលបានចាត់អោយប្រចាំការនៅតាមច្រកទ្វារដែលត្រូវបានអនុញ្ញាតអោយដំណើការត្រូវមានអាកប្បកិរិយាទន់ភ្លន់ រួសរាយរាក់ទាក់ ប៉ុន្តែត្រូវម៉ឺងម៉ាត់ក្នុងការងារ ។ ត្រូវណែនាំអំពីនីតិវិធីនៃការផ្តល់ និងការប្រើប្រាស់ប័ណ្ណឆ្លងដែន ជៀសវាងការផ្តល់ប័ណ្ណទៅអោយមុខសញ្ញាណាដែលមិនត្រូវផ្តល់ ។ ត្រូវណែនាំអំពីរបៀបរបបចាត់ចែងរៀបរយប្រជាពលរដ្ឋខ្មែរ និងបរទេស ដែលមានប័ណ្ណឆ្លងដែនស្របច្បាប់ចេញ-ចូល ឆ្លងកាត់តាមច្រកទ្វារដែលបានអនុញ្ញាត អោយមានសណ្តាប់ធ្នាប់ល្អ ។ ត្រូវណែនាំអោយមានសៀវភៅចុះលេខតាមដានការចេញ-ចូល ឆ្លងកាត់ព្រំដែនរបស់ប្រជាពលរដ្ឋខ្មែរ និងបរទេសអោយបានទៀងទាត់ ។ នៅរៀងរាល់ចុងសប្តាហ៍នីមួយៗ ត្រូវធ្វើសេចក្តីរាយការណ៍ជូនអភិបាលខេត្ត ក្រុង ដែលច្រកទ្វារនោះតាំងនៅ អំពីចំនួនប្រជាពលរដ្ឋខ្មែរ និងបរទេស ដែលបានអនុញ្ញាតអោយចេញ-ចូលឆ្លងកាត់ច្រកទ្វារព្រំដែន ចំនួនអ្នកវិលត្រឡប់

ចេញ-ចូលបានត្រឹមត្រូវ តាមកាលបរិច្ឆេទដែលអនុញ្ញាត ចំនួននិងឈ្មោះអ្នកដែលមិនឃើញវិលត្រឡប់ចេញ និង ចូលមកវិញ ។

នៅរៀងរាល់ចុងខែនីមួយៗ អភិបាលខេត្ត ក្រុងត្រូវសរុបរាយការណ៍មកក្រសួងមហាផ្ទៃ ដើម្បីជាពត៌មានផង ។ ចំពោះអ្នកដែលមិនឃើញវិលត្រឡប់ចេញ-ចូលមកវិញ អភិបាលខេត្ត ក្រុង ត្រូវចាត់ចែងស្រាវជ្រាវរកជាបន្ទាន់ដើម្បីមានវិធានការទាន់ពេលវេលា ។

ទទួលបានសារាចរនេះ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានរដ្ឋបាល សាលាខេត្ត-ក្រុងនៅតាមព្រំដែនកម្ពុជា-ថៃ ត្រូវធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយដល់គ្រប់ភ្នាក់ងារមានសមត្ថកិច្ចពាក់ព័ន្ធ និងអាជ្ញាធរដែនដីក្រោមឱវាទ ជាមួយនោះក៏ត្រូវធ្វើការផ្សព្វផ្សាយស្មារតីនៃសារាចរ និងកិច្ចព្រមព្រៀងកម្ពុជា-ថៃ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ និងស្មារតីនៃកិច្ចប្រជុំគណៈរដ្ឋមន្ត្រីចំរុះកម្ពុជា-ថៃ ចុះថ្ងៃទី៣១ ខែឧសភា និង ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៣ ជូនដល់ប្រជាពលរដ្ឋនៃខេត្តជាប់ព្រំដែនថៃ និងខេត្តសៀមរាប អោយបានយល់ជ្រួតជ្រាប និងអនុវត្តត្រឹមត្រូវគ្រប់ៗគ្នា ។

ស ខេង

*ចំលងជូន :*

*-ទីស្តីការគណៈរដ្ឋមន្ត្រី*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង*

*-គ្រប់ក្រសួង ស្ថាប័ន*

*"ដើម្បីជូនជ្រាប"*

*-គ្រប់អង្គភាពចំណុះក្រសួងមហាផ្ទៃ*

*"ដើម្បីអនុវត្ត"*

*-ឯកសារ*